# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

# តាងនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងរាជធានីភ្នំពេញ

### សាលក្រមព្រហ្មទណ្ឌ

-លេខ: ១១១ "ត១"ព្រ៤
ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០២៣
-សំណុំរឿងព្រហ្មទណ្ឌលេខ: ៥១៩៣
ចុះថ្ងៃទី២៥ ខែសីហា ឆ្នាំ២០២២
-សំណុំរឿងស៊ើបសួរលេខ: ៣១៥០
ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០២២
-សំណុំរឿងជំនុំជម្រះលេខ: ៥១០៤
ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០២២

បានបើកសវនាការជាអហោធារណៈ នៅថ្ងៃពុធ ១១កើត ខែមាឃ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦ ត្រូវនឹងថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០២៣ វេលាម៉ោង ០៨ និង៣០នាទីព្រឹក នៅសាលសវនាការទី១ ដោយមានសមាសភាពដូចតទៅ៖

### ក្រុមប្រឹក្សាជំនុំជម្រះ

-លោក [redacted] ប្រធានក្រុមប្រឹក្សាជំនុំជម្រះ
-លោក [redacted] ចៅក្រមប្រឹក្សា
-លោកស្រី [redacted] ចៅក្រមប្រឹក្សា

### តំណាងអយ្យការ

-លោក [redacted] ព្រះរាជអាជ្ញារងនៃអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ

### ក្រឡាបញ្ជីសវនាការ

-លោកស្រី [redacted] ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ: ៥១៩៣ ចុះថ្ងៃទី២៥ ខែសីហា ឆ្នាំ២០២២ ដែលមានជនជាប់ចោទ៖

១/.ឈ្មោះ [redacted] ចាន់ថៃ ភេទប្រុស អាយុ ២១ឆ្នាំ ជនជាតិខ្មែរ សាសនាព្រះពុទ្ធ មុខរបរ មិនពិតប្រាកដ មានទីកន្លែងកំណើតស្ថិតនៅសង្កា[redacted] រាជធានីភ្នំពេញ ទីលំនៅមុនពេលឃាត់ខ្លួនស្នាក់នៅភូមិត្រពាំងស្គន់ សង្កាត់ពន្សាំង ខណ្ឌសែនសុខ រាជធានីភ្នំពេញ។ ឪពុកឈ្មោះ [redacted] ចាន់ថា "រស់" ម្តាយឈ្មោះ [redacted] ផល្លី "រស់" នៅលីវ ជានីតិជន ទោសពីមុន៖ គ្មាន។

-ឃុំខ្លួននៅមណ្ឌលអប់រំកែប្រែទី១ (ម១) តាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ៧០៣៣ "ង១" ដ.ឃ.ដ ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០២២។

-លោកស្រីមេធាវី [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ។

២/.ឈ្មោះ [redacted] ណារ៉ា ហៅ ចាន់ ភេទប្រុស អាយុ ១៧ឆ្នាំ ជនជាតិខ្មែរ សាសនាព្រះពុទ្ធ មុខរបរ មិនពិតប្រាកដ មានទីកន្លែងកំណើតស្ថិតនៅសង្កាត់[redacted] រាជធានីភ្នំពេញ ទីលំនៅមុនពេលឃាត់ខ្លួនស្នាក់នៅភូមិសែនសុខ៥ សង្កាត់ឃ្មួញ ខណ្ឌសែនសុខ រាជធានីភ្នំពេញ។ ឪពុកឈ្មោះ [redacted] ចាន់ថា "រស់" ម្តាយឈ្មោះ [redacted] សុខ "រស់" នៅលីវ ជាអនីតិជន ទោសពីមុន៖ គ្មាន។

-ឃុំខ្លួននៅពន្ធនាគាររាជធានីភ្នំពេញ (PJ) តាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ៧០៣២ "ង១" ដ.ឃ.ដ ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០២២។

-លោកស្រីមេធាវី [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ។

-ជាប់ចោទពីបទៈ លួចមានស្ថានទម្ងន់ទោស ប្រព្រឹត្តនៅចំណុចផ្លូវបេតុង ភូមិខ្មែរលើ សង្កាត់គោករកា ខណ្ឌព្រែកព្នៅ រាជធានីភ្នំពេញ កាលពីថ្ងៃទី២៣ ខែសីហា ឆ្នាំ២០២២។ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៥៣ និងមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] សាម៉ន ភេទស្រី អាយុ ១៨ឆ្នាំ ជនជនជាតិខ្មែរ មានអាសយដ្ឋានបច្ចុប្បន្នស្នាក់នៅ ផ្ទះលេខ ១២ ផ្លូវបេតុង ភូមិខ្មែរលើ សង្កាត់គោករកា ខណ្ឌព្រែកព្នៅ រាជធានីភ្នំពេញ។

## អង្គហេតុនៃរឿងមានដូចតទៅ

-កាលពីថ្ងៃទី២៣ ខែសីហា ឆ្នាំ២០២២ វេលាម៉ោង ១៤ និង០០នាទី ជនរងគ្រោះឈ្មោះ [redacted] សាម៉ន បានយកទូរស័ព្ទដៃម៉ាករៀលមី ពណ៌ខៀវ ចំនួន ០១គ្រឿង កាន់នៅក្នុងដៃឆ្វេង រួចជួយរុញម៉ូតូរបស់បងស្រីបង្កើតឈ្មោះ [redacted] ស្រីពៅ ម៉ាកស្កុបពីពណ៌ខ្មៅ ពាក់ផ្លាកលេខ ភ្នំពេញ 1II-1489 ដែលខូចចេញពីផ្ទះលេខ ១២ ផ្លូវបេតុង ភូមិខ្មែរលើ សង្កាត់គោករកា ខណ្ឌព្រែកព្នៅ រាជធានីភ្នំពេញ ក្នុងគោលបំណងយកទៅជួសជុលម៉ូតូនៅផ្លូវ២០១១ ភូមិសង្កាត់ជាមួយគ្នា។ លុះពេលជនរងគ្រោះឈ្មោះ [redacted] សាម៉ន ធ្វើដំណើរបានប្រហែល ២០០ម៉ែត្រ ស្រាប់តែមានមនុស្សចំនួន ០២នាក់ ឈ្មោះ [redacted] ចាន់ថៃ និងឈ្មោះ [redacted] ណារ៉ា ជិះម៉ូតូម៉ាក ស៊ុយស៊ីគីនិច ពណ៌សខៀវ សេរីឆ្នាំ២០១៩ ពាក់ផ្លាកលេខ ភ្នំពេញ 1FQ-2508 ចំនួន ០១គ្រឿង ទៅអែបពីចំហៀងខាងឆ្វេងជនរងគ្រោះ ភ្លាមនោះជនជាប់ចោទឈ្មោះ [redacted] ណារ៉ា បានធ្វើសកម្មភាពឆក់ទូរស័ព្ទដៃពីដៃខាងស្តាំជនរងគ្រោះ ហើយនាំគ្នាជិះម៉ូតូគេចខ្លួនតាមបណ្តោយផ្លូវ២០១១ ក្នុងទិសដៅពីត្បូងទៅជើងបាត់ ហើយជនរងគ្រោះបានស្រែកឆោឡោ។ ភ្លាមនោះកម្លាំងសមត្ថកិច្ចប៉ុស្តិ៍នគរបាលរដ្ឋបាលគោករកាកំពុងល្បាតនៅក្បែរ ក៏បានអន្តរាគមន៍ដេញស្ទាក់ចាប់បានជនជាប់ចោទទាំងពីរនាក់ រួមទាំងវត្ថុតាងរួចក៏យកទៅសាកសួរនៅប៉ុស្តិ៍នគរបាលរដ្ឋបាលគោករកាតែម្តង។ ជនជាប់ចោទទាំងពីរនាក់បានសារភាពថា ពួកខ្លួនគឺជាក្រុមចោរឆក់យ៉ាងសកម្មភាពនៅទីក្រុងភ្នំពេញសឹងតែជារៀងរាល់យប់ និងធ្លាប់ប្រព្រឹត្តករណីឆក់ជាច្រើនលើក។

-បានឃើញ របាយការណ៍សំយោគលេខ ៦១/២២ រ.ប.ក ចុះថ្ងៃទី២៤ ខែសីហា ឆ្នាំ២០២២ របស់អធិការដ្ឋាននគរបាលខណ្ឌព្រែកព្នៅ នៃស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ។

-បានឃើញ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ ៣២០៧ អ.យ.ក ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០២២ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

-បានឃើញ ដីកាសន្និដ្ឋានស្ថាពរលេខ ៤០៧៩ អ.យ.ក ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០២២ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

-បានឃើញ ដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ ៥៤៤៩ "ង១"ជ.ជ ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ២០២២ របស់សាលាដំបូងរាជធានីភ្នំពេញ។

## នាពេលសវនាការ

-ជនជាប់ចោទឈ្មោះ [redacted] ចាន់ថៃ និងឈ្មោះ [redacted] ណារ៉ា ហៅ ចាន់ បានឆ្លើយសារភាពប្រហាក់ប្រហែលគ្នាថាៈ ពួកខ្លួនបានដឹងពីបទចោទប្រកាន់រួចហើយ។ ពួកខ្លួនពិតជាបានប្រព្រឹត្តដូចការចោទប្រកាន់ពិតមែន។ នៅថ្ងៃកើតហេតុ ពួកខ្លួនឃើញជនរងគ្រោះកំពុងរុញម៉ូតូ និងឃើញដៃកាន់ទូរស័ព្ទដៃ ពេលនោះពួកខ្លួនក៏បានជិះម៉ូតូទៅអែបនឹងជនរងគ្រោះ រួចធ្វើសកម្មភាពឆក់យកទូរស័ព្ទដៃបានសម្រេច រួចជិះគេចខ្លួន ហើយក៏ត្រូវបានជនរងគ្រោះស្រែកថា ចោរៗ ពេលនោះក៏មានសមត្ថកិច្ចដែលកំពុងល្បាតក្បែរជិះដេញតាមចាប់ពួកខ្លួនបានតែម្តង។

-ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] សាម៉ន បានឆ្លើយថា នៅថ្ងៃកើតហេតុ ម៉ូតូបងស្រីរបស់ខ្លួនខូច ខ្លួនក៏បានជួយរុញម៉ូតូបងស្រីរបស់ខ្លួន ដើម្បីយកទៅដាក់ឱ្យជាងជួសជុល ស្រាប់តែពេលរុញនោះ ជនជាប់ចោទទាំងពីរនាក់នេះក៏បានជិះម៉ូតូមកអែប រួចឆក់យកទូរស័ព្ទដៃរបស់ខ្លួនយកទៅបាត់ និងបណ្ដាលឱ្យបងស្រីរបស់ខ្លួនដួលសន្លប់ទៅលើផ្លូវ ហើយខ្លួនក៏បានស្រែកថា ចោរៗ រួចក៏មានសមត្ថកិច្ចល្បាតក្បែរនោះជួយអន្តរាគមន៍ចាប់ខ្លួនជនជាប់ចោទទាំងពីរនាក់នេះបាន។ នៅក្នុងរឿងនេះ ខ្លួនសូមទាមទារសំណងជាប្រាក់ថ្លៃថ្នាំព្យាបាល និងសំណងជំងឺចិត្តចំនួន ២.០០០(ពីរពាន់)ដុល្លារអាមេរិក។

-តាមរំណានរបាយការណ៍សំយោគលេខ ៦១/២២ រ.ប.ក ចុះថ្ងៃទី២៤ ខែសីហា ឆ្នាំ២០២២ របស់អធិការដ្ឋាននគរបាលខណ្ឌព្រែកព្នៅ នៃស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញបានសន្និដ្ឋានថា ជនសង្ស័យឈ្មោះ [redacted] ចាន់ថៃ ភេទប្រុស អាយុ ២១ឆ្នាំ ជនជាតិខ្មែរ (ឃាត់ខ្លួន) និងឈ្មោះ [redacted] ណារ៉ា ហៅ ចាន់ ភេទប្រុស អាយុ ១៧ឆ្នាំ ជនជាតិខ្មែរ (ឃាត់ខ្លួន) ពិតជាបានប្រព្រឹត្តបទល្មើស លួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា (ឆក់យកទូរស័ព្ទដៃ) របស់ជនរងគ្រោះឈ្មោះ [redacted] សាម៉ន ភេទស្រី អាយុ ១៦ឆ្នាំ នៅចំណុចផ្លូវ២០១១ ភូមិខ្មែរលើ សង្កាត់គោករកា ខណ្ឌព្រែកព្នៅ រាជធានីភ្នំពេញ កាលពីថ្ងៃទី២៣ ខែសីហា ឆ្នាំ២០២២ វេលាម៉ោង ១៤ និង០០នាទីប្រហែលមែន។

## សេចក្ដីសន្និដ្ឋានម្ដីឧសុំរបស់តំណាងអយ្យការ

-តំណាងអយ្យការបានធ្វើសេចក្ដីសន្និដ្ឋានថា: ក្រោយពីបានស្ដាប់ចម្លើយសារភាពរបសជនជាប់ចោទម្នាក់ៗនាពេលសវនាការ ក្រោយពីបានស្ដាប់ក្រឡាបញ្ជីអានរបាយការណ៍សំយោគ និងក្រោយពីបានពិនិត្យភស្តុតាងនានាក្នុងសំណុំរឿងរួចមកឃើញថា ជនជាប់ចោទឆ្លើយសារភាពអំពីទង្វើប្រព្រឹត្តរបស់ខ្លួនអស់ហើយ។ តាមចម្លើយសារភាពរបស់ជនជាប់ចោទទាំងនេះ គឺមានភាពស៊ីសង្វាក់គ្នានឹងរបាយការណ៍របស់សមត្ថកិច្ច។ ហេតុដូច្នេះតំណាងអយ្យការស្នើសុំតម្កល់បទចោទប្រកាន់ពីបទ លួចមានស្ថានទម្ងន់ទោស ប្រព្រឹត្តនៅចំណុចផ្លូវបេតុង ភូមិខ្មែរលើ សង្កាត់គោករកា ខណ្ឌព្រែកព្នៅ រាជធានីភ្នំពេញ កាលពីថ្ងៃទី២៣ ខែសីហា ឆ្នាំ២០២២។ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា ៣៥៣ និងមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ ដូចមានក្នុងដីកាសន្និដ្ឋានស្ថាពរលេខ ៥៤៤៩ "ង១"ង.ដ ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ២០២២ ទុកជាបានការដដែល និងស្នើសុំឱ្យតុលាការផ្ដន្ទាទោសជនជាប់ចោទទាំងនេះតាមច្បាប់។

## សេចក្ដីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ

-លោកស្រីមេធាវី [redacted] បានធ្វើសេចក្ដីសន្និដ្ឋានថា: ក្រោយពីបានស្ដាប់ចម្លើយរបស់កូនក្ដីម្នាក់ៗនាពេលសវនាការ ក្រោយពីបានស្ដាប់ក្រឡាបញ្ជីអានរបាយការណ៍សំយោគ ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានរបស់តំណាងអយ្យការ និងក្រោយពីបានពិនិត្យឯកសារនានាក្នុងសំណុំរឿងរួចមកឃើញថា នៅក្នុងរឿងនេះ កូនក្ដីខ្លួនម្នាក់ៗបានសហការឆ្លើយសារភាពតាំងពីដំណាក់កាលនគរបាលយុត្តិធម៌ រហូតមកដល់ពេលសវនាការនេះ ដោយចម្លើយរបស់កូនក្ដីខ្លួនមិនមានអ្វីប្រែប្រួលនោះទេ។ នៅពេលកូនក្ដីខ្លួនធ្វើសកម្មភាពនោះ គឺមិនបានបង្កឱ្យមានព្យសនកម្មធ្ងន់ធ្ងរនោះដែរ ហេតុនេះស្នើសុំតុលាការកែប្រែបទចោទប្រកាន់លើកូនក្ដីខ្លួនពីបទ លួចមានស្ថានទម្ងន់ទោស តាមបញ្ញត្តិមាត្រា ៣៥៣ និងមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ មកបទ លួច តាមបញ្ញត្តិមាត្រា ៣៥៣ និងមាត្រា ៣៥៦ នៃក្រមព្រហ្មទណ្ឌវិញ និងស្នើសុំជួយបន្ធូរបន្ថយទោសដល់កូនក្ដីខ្លួនផង។

## សម្ដីចុងក្រោយរបស់ជនជាប់ចោទ

-ជនជាប់ចោទម្នាក់ៗបានស្នើសុំឱ្យតុលាការជួយបន្ធូរបន្ថយទោសដល់ពួកខ្លួនផង។

-ក្រោយពីបានស្ដាប់ចម្លើយជនជាប់ចោទម្នាក់ៗ។

-ក្រោយពីបានស្ដាប់ចម្លើយរបស់ដើមបណ្ដឹងរដ្ឋប្បវេណី។

-ក្រោយពីបានស្តាប់ក្រឡាបញ្ជីអានរបាយការណ៍សំយោគ។

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ។

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ។

-ក្រោយពីបានស្តាប់សម្តីចុងក្រោយរបស់ជនជាប់ចោទម្នាក់ៗ។

-ក្រោយពីបានពិនិត្យលើឯកសារ ភស្តុតាងនានា។

-ក្រោយពីបានពិចារណាត្រឹមត្រូវតាមច្បាប់ហើយ។

## សំអាងហេតុ

១/.តាមដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ ៥៤៤៩ "ង១"ដ.ដ ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ២០២២ របស់ចៅក្រមស៊ើបសួរ បានសម្រេចបញ្ជូនខ្លួនជនជាប់ចោទឈ្មោះ [redacted] ចាន់ថៃ ភេទប្រុស អាយុ ២១ឆ្នាំ ជនជាតិខ្មែរ និងឈ្មោះ [redacted]ណារ៉ា ហៅ ចាន់ ភេទប្រុស អាយុ ១៧ឆ្នាំ ជនជាតិខ្មែរ មកជំនុំជម្រះពីបទ លួចមានស្ថានទម្ងន់ទោស ប្រព្រឹត្តនៅចំណុចផ្លូវបេតុង ភូមិខ្មែរលើ សង្កាត់គោករកា ខណ្ឌព្រែកព្នៅ រាជធានីភ្នំពេញ កាលពីថ្ងៃទី២៣ ខែសីហា ឆ្នាំ២០២២។ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៥៣ និងមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ។

២/.ជនជាប់ចោទម្នាក់ៗ បានឆ្លើយសារភាពប្រហាក់ប្រហែលគ្នាថា នៅថ្ងៃកើតហេតុ ពួកខ្លួនឃើញជនរងគ្រោះកំពុងរុញម៉ូតូ និងឃើញដៃកាន់ទូរស័ព្ទ ពេលនោះពួកខ្លួនក៏បានជិះទៅអែបទឹងជនរងគ្រោះ រួចធ្វើសកម្មភាពឆក់យកទូរស័ព្ទដែលបានសម្រេច រួចជិះគេចខ្លួន ហើយក៏ត្រូវបានជនរងគ្រោះស្រែកថា ចោរៗ ពេលនោះក៏មានសមត្ថកិច្ចដែលកំពុងល្បាតក្បែរជិះដេញតាមចាប់ពួកខ្លួនបានតែម្តង។ អំពើរបស់ជនជាប់ចោទខាងលើគឺជាបទល្មើសជាក់ស្តែង បានធ្វើឱ្យប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់សន្តិសុខ សណ្តាប់ធ្នាប់សង្គម និងរបៀបរៀបរយសាធារណៈ គប្បីតុលាការដាក់ទោសជនទាំងនេះតាមច្បាប់។

៣/.ដើមបណ្តឹងរដ្ឋប្បវេណីបានអះអាងទាមទារសំណងថ្លៃថ្នាំព្យាបាល និងសំណងជំងឺចិត្តចំនួន ២.០០០(ពីរពាន់)ដុល្លារអាមេរិកនោះ គប្បីតុលាការពិនិត្យសម្រេចតាមច្បាប់។

៤/.វត្ថុចាប់យករួមមាន៖

ក/.ម៉ូតូចំនួន ០១គ្រឿង ម៉ាក ស៊ុយស៊ីគីនិច ពណ៌ស-ខៀវ ពាក់ផ្លាកលេខ ភ្នំពេញ 1FQ-2508 (មិនប្រក្រតី) គប្បីតុលាការសម្រេចរឹបអូសទុកជាសម្បត្តិរដ្ឋ។

ខ/.ទូរស័ព្ទចំនួន ០២គ្រឿង ម៉ាកអាយហ្វូន ពណ៌ខ្មៅ (មិនដំណើរការ) និងម៉ាកអាយហ្វូន ពណ៌ទឹកមាស (បែកសំបកក្រោយ) គប្បីតុលាការសម្រេចរឹបអូស និងបំផ្លាញចោល។

៥/.សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការនៅតែស្នើសុំតម្កល់បទចោទប្រកាន់ទុកជាបានការទាំងមូល និងសុំឱ្យតុលាការផ្តន្ទាទោសជនជាប់ចោទទាំងនេះតាមច្បាប់ មានលក្ខណៈសមហេតុសមផល គប្បីតុលាការពិនិត្យសម្រេចតាមច្បាប់។

៦/.សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ ស្នើសុំតុលាការកែប្រែបទចោទប្រកាន់លើកូនក្តីខ្លួនពីបទ លួចមានស្ថានទម្ងន់ទោស តាមបញ្ញត្តិមាត្រា ៣៥៣ និងមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ មកបទ លួច តាមបញ្ញត្តិមាត្រា ៣៥៣ និងមាត្រា ៣៥៦ នៃក្រមព្រហ្មទណ្ឌវិញ និងស្នើសុំតុលាការជួយបន្ធូរបន្ថយទោសដល់កូនក្តីខ្លួនផងនោះ គប្បីតុលាការពិនិត្យសម្រេចតាមច្បាប់។

៧/.សម្តីចុងក្រោយរបស់ជនជាប់ចោទម្នាក់ៗ សំណូមពរសុំតុលាការជួយបន្ធូរបន្ថយទោសដល់ពួកខ្លួនផងនោះ គប្បីតុលាការពិនិត្យសម្រេចតាមច្បាប់។



Scanned with CamScanner

៨/.មានពិរុទ្ធភាពគ្រប់គ្រាន់ដើម្បីដាក់បន្ទុកលើឈ្មោះ [redacted] ចាន់ថៃ ភេទប្រុស អាយុ ២១ឆ្នាំ ជនជាតិខ្មែរ និងឈ្មោះ [redacted] ណារ៉ាំ ហៅ ចាន់ ភេទប្រុស អាយុ ១៧ឆ្នាំ ជនជាតិខ្មែរ ពីបទ លួចមានស្ថានទម្ងន់ទោស ប្រព្រឹត្តនៅចំណុចផ្លូវបេតុង ភូមិខ្មែរលើ សង្កាត់គោករកា ខណ្ឌព្រែកព្នៅ រាជធានីភ្នំពេញ កាលពីថ្ងៃទី២៣ ខែសីហា ឆ្នាំ២០២២។ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៥៣ និងមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ។

**ហេតុដូច្នេះសម្រេច**

១/.ផ្តន្ទាទោសលើ៖

ក/.ឈ្មោះ [redacted] ចាន់ថៃ ភេទប្រុស អាយុ ២១ឆ្នាំ ជនជាតិខ្មែរ ដាក់ពន្ធនាគារកំណត់ចំនួន ០៣(បី)ឆ្នាំ ដែលបច្ចុប្បន្នជននេះជាប់ឃុំខ្លួននៅមណ្ឌលអប់រំកែប្រែទី១ (ម១) នៃក្រសួងមហាផ្ទៃ។

ខ/.ឈ្មោះ [redacted] ណារ៉ាំ ហៅ ចាន់ ភេទប្រុស អាយុ ១៧ឆ្នាំ ជនជាតិខ្មែរ ដាក់ពន្ធនាគារកំណត់ចំនួន ១៨(ដប់ប្រាំបី)ខែ ដែលបច្ចុប្បន្នជននេះជាប់ឃុំខ្លួននៅពន្ធនាគាររាជធានីភ្នំពេញ (PJ) នៃក្រសួងមហាផ្ទៃ។

-ការផ្តន្ទាទោសជនជាប់ចោទទាំងពីរនាក់ខាងលើពីបទ លួចមានស្ថានទម្ងន់ទោស ប្រព្រឹត្តនៅចំណុចផ្លូវបេតុង ភូមិខ្មែរលើ សង្កាត់គោករកា ខណ្ឌព្រែកព្នៅ រាជធានីភ្នំពេញ កាលពីថ្ងៃទី២៣ ខែសីហា ឆ្នាំ២០២២។ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ១៦០, មាត្រា ៣៥៣ និងមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ។

២/.បង្គាប់ឱ្យឈ្មោះ [redacted] ចាន់ថៃ និងឈ្មោះ [redacted] ណារ៉ាំ ហៅ ចាន់ រួមគ្នាសងថ្លៃថ្នាំព្យាបាល និងសំណងជំងឺចិត្តចំនួន ៦០០.០០០(ប្រាំមួយរយពាន់)រៀល ឱ្យទៅឈ្មោះ [redacted] សាម៉ន ជាដើមបណ្តឹងរដ្ឋប្បវេណី។ សំណូមពរលើសពីនេះច្រានចោល។

៣/.វត្ថុចាប់យករួមមាន៖

ក/.ម៉ូតូចំនួន ០១គ្រឿង ម៉ាក ស៊ុយស៊ីគីនិច ពណ៌ស-ខៀវ ពាក់ផ្លាកលេខ ភ្នំពេញ 1FQ-2508 (មិនប្រក្រតី) សម្រេចរឹបអូសទុកជាទ្រព្យសម្បត្តិរដ្ឋ តាមបញ្ញត្តិមាត្រា ៦២ នៃក្រមព្រហ្មទណ្ឌ។។

ខ/.ទូរស័ព្ទចំនួន ០២គ្រឿង ម៉ាកអាយហ្វូន ពណ៌ខ្មៅ (មិនដំណើរការ) និងម៉ាកអាយហ្វូន ពណ៌ទឹកមាស (បែកសំបកក្រោយ) សម្រេចរឹបអូស និងបំផ្លាញចោល តាមបញ្ញត្តិមាត្រា ៦២ នៃក្រមព្រហ្មទណ្ឌ។

៤/.សាលក្រមនេះជំនុំជម្រះជាអសាធារណៈ នៅថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០២៣ និងប្រកាសជាអសាធារណៈ នៅថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០២៣ ចំពោះមុខជនជាប់ចោទ មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ ចំពោះមុខដើមបណ្តឹងរដ្ឋប្បវេណី សម្រេចបើកផ្លូវប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់។

**ក្រឡាបញ្ជីសវនាការ** **ចៅក្រមប្រឹក្សា** **ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

ហត្ថលេខានិងត្រា: [redacted]

................................................................................................................................

បានឃើញ

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

[redacted]

"បានចម្លងត្រឹមត្រូវតាមច្បាប់ដើម"

ថ្ងៃពុធ ១១កើត ខែមាឃ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

រាជធានីភ្នំពេញ, ថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០២៣

**ក្រឡាបញ្ជី**

[redacted]



Scanned with CamScanner